ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ៧៤៨ ក.ប/ស.ជ.៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជូនដំណឹងអំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ របស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមជូនដំណឹងដល់សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីអនុវត្តតាមស្មារតីនៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាពដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថានឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និង ប្រកបដោយភាពទទួលខុសត្រូវនោះ ភាគីពាក់ព័ន្ធត្រូវមានកាតព្វកិច្ចអនុវត្តដូចខាងក្រោម៖

១-ភាគីសហជីពកម្មករនិយោជិត

- មានកាតព្វកិច្ចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីនិយោជកឱ្យបានច្បាស់លាស់អំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថាន ទៅតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ រួមទាំងការផ្ញើតាមរយៈលិខិតអនុសិដ្ឋផង។
- មានកាតព្វកិច្ចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (អាសយដ្ឋាន អគារអគ្គនាយកដ្ឋានការងារ ជាន់ទី០២ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ) ឱ្យបានច្បាស់លាស់អំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថាន ដើម្បីឱ្យនាយកដ្ឋានវិវាទការងារ មានមូលដ្ឋានក្នុងការចម្លងជូន ឬផ្តល់ព័ត៌មានបន្ថែមទៅភាគីនិយោជកនៃ សហគ្រាស គ្រឹះស្ថាន តាមការដាក់ស្នើ។

២-ភាគីនិយោជក

- មានកាតព្វកិច្ចទទួលនូវរាល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានផ្ញើជូនដោយភាគីសហជីពកម្មករនិយោជិត អំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថាន។

- មានកាតព្វកិច្ចទទួលយកនូវរាល់លិខិតជូនដំណឹង ឬព័ត៌មានបន្ថែមអំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថានរបស់ខ្លួនដែលបានផ្តល់ជូនដោយនាយកដ្ឋានវិវាទការងារទៅតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ រួមទាំងការផ្ញើតាមរយៈលិខិតអនុសិដ្ឋផង។

- មានកាតព្វកិច្ចចុះហត្ថលេខាទទួលដោយមានបញ្ជាក់ កាលបរិច្ឆេទ ឈ្មោះ ភេទ និងតួនាទី នៃអ្នកទទួលឱ្យបានច្បាស់លាស់លើលិខិតជូនដំណឹង អំពីបញ្ជីឈ្មោះបេក្ខភាពដែលនឹងត្រូវឈរឈ្មោះឱ្យគេបោះឆ្នោត និងបញ្ជីឈ្មោះបេក្ខភាពដែលបានជាប់ឆ្នោតជាថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតប្រចាំសហគ្រាស គ្រឹះស្ថាន ដែលបានផ្ញើជូនដោយភាគីពាក់ព័ន្ធ។

ក្នុងករណីចាំបាច់ នាយកដ្ឋានវិវាទការងារ មានភារកិច្ចសម្របសម្រួលនូវរាល់បញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងការជូនដំណឹងខាងលើ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីថ្នាក់ដឹកនាំសហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ពិតជាយកចិត្តទុកដាក់អនុវត្តតាមសេចក្តីជូនដំណឹងខាងលើរបស់ក្រសួងបានល្អប្រសើរជាមិនខាន។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីពកម្មករនិយោជិត
"ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ -កាលប្បវត្តិ